# សុន្ទរកថា

## របស់ លោកវេជ្ជបណ្ឌិត RICHNER ក្នុងពិធីបញ្ចុះបឋមសិលា
## សាងសង់សាខាមន្ទីរពេទ្យកុមារ គន្ធបុប្ផា
## ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥

៙ ✿ ៚

***សូមក្រាបថ្វាយបង្គំ***

**ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន និង សម្តេចព្រះមហេសី នរោត្តម មុនិនាថ សីហនុ ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រ កម្ពុជា**

***សូមគោរព*** **សម្តេច ជា ស៊ីម**

***សូមក្រាបថ្វាយបង្គំ*** **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ**

***សូមគោរព*** **សម្តេច ហ៊ុន សែន**

***សូមគោរព*** **ឯកឧត្តម,លោកជំទាវ, លោក, លោកស្រី, កុមារទាំងឡាយ នៃ ព្រះរាជាណាចក្រកម្ពុជា**

នៅក្នុងអំឡុងឆ្នាំ ៦០ **ព្រះករុណា ជាអម្ចាស់** បានសង់មន្ទីរពេទ្យកុមារ ដែលមានឈ្មោះថា មន្ទីរពេទ្យកុមារ **គន្ធបុប្ផា** ដើម្បីរំលឹកដល់ព្រះរាជបុត្រីព្រះអង្គ ដែលបានសុគតដោយរោគមហារីកឈាម ។ នៅឆ្នាំ១៩៧៤ _ ៧៥ ទូលព្រះបង្គំបានធ្វើការនៅក្នុងមន្ទីរពេទ្យនេះ ជាវេជ្ជបណ្ឌិតខាងរោគកុមារ ។ តាមសំណូមពររបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល នៅឆ្នាំ១៩៩២ យើងខ្ញុំបានធ្វើការជួសជុលធ្វើមន្ទីរពេទ្យនេះឡើងវិញ ហើយបានធ្វើការសម្ពោធមន្ទីរពេទ្យនេះ ក្រោមព្រះរាជាធិបតីភាពរបស់ **ព្រះករុណា ជាអម្ចាស់** នៅខែកញ្ញា ឆ្នាំ១៩៩២ ។

**ព្រះករុណា ជាអម្ចាស់ , សម្តេច ព្រះមហេសី**

**សម្តេច , លោកស្រី , អស់លោក**

កុមារទាំងឡាយ ដែលបានចូលមកព្យាបាលក្នុងមន្ទីរពេទ្យ **គន្ធបុប្ផា** សុទ្ធតែមានជម្ងឺធ្ងន់ធ្ងរខ្លាំងណាស់ ហើយសុទ្ធតែជាកុមារដែលកំព្រាលំបាកមែនទែន ។ ដូចនេះហើយ ទើបឳពុកម្តាយពួកគេមិនបានចេញថ្លៃព្យាបាលទេ ។ ពួកគេទទួលការព្យាបាលគ្រប់យ៉ាងដោយឥតគិតថ្លៃ ។ កុមារទាំងនោះច្រើនតែមានជម្ងឺច្រើនយ៉ាងព្រមគ្នា ។ តាំងពីខែ តុលា ឆ្នាំ ១៩៩៤មក យើងលែងមានលទ្ធភាពនឹងទទួលកុមារទាំងអស់ដែលត្រូវការចូលសំរាកព្យាបាលក្នុងមន្ទីរពេទ្យហើយ ។ នាវារបស់យើងពេញហើយ ពេញហួសដោយបានទទួលកុមាររហូតដល់២៦០នាក់។ ទូលព្រះបង្គំ យើងខ្ញុំបានខិតខំអស់សមត្ថភាព ដើម្បីបង្កើនលទ្ធភាពទទួលសព្វថ្ងៃនេះចំនួនគ្រែឡើងដល់២៤០។ បើកុមារមានចំនួនលើសពី ២៤០ នាក់ គេមិនអាចនឹងថែទាំព្យាបាលកុមារមានជម្ងឺទាំងអស់ អោយបានត្រឹមត្រូវទេ ។ ពីមួយថ្ងៃទៅមួយថ្ងៃ យើងត្រូវធ្វើការជ្រើសរើស តើក្មេងណាត្រូវទទួល ក្មេងណាមិនត្រូវទទួល ។ ទូលព្រះបង្គំយើងខ្ញុំទទួលតែកុមារណាដែលឈឺធ្ងន់មែនទែន ។

ពិបាកនឹងធ្វើការជ្រើសរើសដូចនេះណាស់ ចំពោះបុគ្គលិកទូលព្រះបង្គំយើងខ្ញុំ ពិបាកនឹងទ្រាំទ្រការនេះជាពិសេសនៅពេលម៉ោងយាមប្រចាំការ ។ ចំណែកខាងកុមារដែលមិនបានចូលសំរាកព្យាបាល ចំពោះឪពុកម្តាយគេ តែងមានការថ្នាំងថ្នាក់ នេះជាគ្រោះថ្នាក់ នេះជាសោកនាដកម្ម ។ ទូលព្រះបង្គំ យើងខ្ញុំមិនអាចដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរនេះបានរហូតដល់ថ្ងៃ ដែលទូលព្រះបង្គំយើងខ្ញុំបានទទួលព្រះអំណោយដែលមិនបាននឹកស្មានដល់នូវព្រះរាជអំណោយអស្ចារ្យដែលធ្លាក់ពីលើមេឃមកគឺថា **ព្រះករុណា** ទ្រង់ប្រោសប្រទានលទ្ធភាពអោយកសាងសាខាមន្ទីរពេទ្យកុមារ **គន្ធបុប្ផា** មួយ នៅក្នុងបរិវេណព្រះបរមរាជវាំង ។

ព្រះរាជកាយវិការនេះមានតែមួយគត់ តើមានព្រះមហាក្សត្រអង្គណា ដែលមានព្រះរាជហឫទ័យសប្បុរសធម៌ ប្រោសប្រទានសួនច្បាររបស់ព្រះអង្គ ដើម្បីសង្គ្រោះជីវិតកុមារដែលមានជម្ងឺ និង កុមារដែលក្រខ្សត់មែនទែននោះ? ព្រះរាជកាយវិការនេះ ជានិម្មិតរូបមួយ ហើយបង្ហាញពីឯកសិទ្ធិ ចំពោះមនុស្សទាំងអស់ នៅប្រទេសកម្ពុជា , ប្រទេសស្វីស និង នៅប្រទេសឯទៀត គឺថានៅគ្រប់ទីកន្លែង ពីឯកសិទ្ធិក្នុងការជួយសង្គ្រោះកុមារក្រខ្សត់ដែលមានជម្ងឺ ។ ព្រះរាជកាយវិការនេះ ត្រូវរាប់ជាព្រឹត្តការណ៍ប្រវត្តិសាស្ត្រ ។ តើកុមារមិនជាបេះដូង ជាព្រលឹងរបស់ប្រជាជននិមួយៗ គឺថាអនាគតរបស់ប្រទេសជាតិទេឬ ទូលព្រះបង្គំ យើងខ្ញុំ ចង់ទូលថ្វាយថា កុមារជាបេះដូង និង ជាព្រលឹងរបស់ពិភពលោក ។

សាខាមន្ទីរពេទ្យកុមារ គន្ធបុប្ផា នេះ នឹងមានគ្រែ ១៦៤ ដោយមានផ្នែកសង្គ្រោះបន្ទាន់ មានគ្រែ ៣៤ និង មានមណ្ឌលទទួលពិនិត្យរោគ និង ការពារព្យាបាល ។ យើងខ្ញុំវាយតម្លៃថា ការសាងសង់ត្រូវប្រើទឹកប្រាក់ ចំនួនពី ១,២ ទៅ ១,៥ លានដុល្លារអាមេរិក ឯចំពោះការបំពាក់សំភារៈបរិក្ខា ត្រូវប្រើទឹកប្រាក់ចំនួន ០,៧ លានដុល្លារអាមេរិក ។

## ព្រះករុណា ថ្លៃវិសេស

ព្រះរាជកាយវិការដែលមានតែមួយនេះ ក៏ជាសក្ខីភាពបង្ហាញពីព្រះរាជហឫទ័យទុកចិត្តរបស់ព្រះអង្គចំពោះការងាររបស់យើងខ្ញុំ នៅមន្ទីរពេទ្យកុមារ **គន្ធបុប្ផា** ដែរ ។ សូម **ព្រះករុណា ជាអម្ចាស់** មេត្តាអនុញ្ញាតដល់ទូលព្រះបង្គំទូលថ្វាយជាថ្មីទៀត ក្នុងនាមបុគ្គលិកទាំងអស់ នៃមន្ទីរពេទ្យ **គន្ធបុប្ផា** នូវ អំណរព្រះគុណចំពោះ **ព្រះករុណា** ព្រមទាំង **សម្តេច ព្រះមហេសី** ដែលបានប្រទានកិត្តិយសដល់ទូលព្រះបង្គំយើងខ្ញុំ ដោយបានយាងមកទតមន្ទីរពេទ្យយើងខ្ញុំ កាលពីខែកញ្ញា ឆ្នាំ ១៩៩៤ នៅក្នុងពេលម៉ោងធ្វើការដែលជាព្រះរាជកាយវិការមួយដ៏សំខាន់ និង ជាការលើកទឹកចិត្តដល់មន្ត្រីរាជការយើងខ្ញុំទាំងអស់ ។

ហេតុអ្វីបានជាមន្ទីរពេទ្យកុមារ **គន្ធបុប្ផា** មានដំណើរការល្អ? ប្រហែលចម្លើយសាមញ្ញបំផុត :

គឺថាអ្វីៗ ដែលយើងបានធ្វើ មិនមែនជាជំនួយ ឬការជួយថែជម្ងឺអ្នកក្រីក្រទេ តែជាការលុបលាងកំហុស ។ តាមការយល់ឃើញរបស់ទូលព្រះបង្គំ ខ្ញុំ ផ្ទាល់ខ្លួន បញ្ហាទាំងឡាយនៅក្នុងអំឡុងឆ្នាំ ៧០ គឺត្រូវបានបណ្តាលអោយមានឡើងដោយពួកបស្ចិមប្រទេស គឺជាកំហុសដ៏ធ្ងន់ធ្ងរ ដែលគេមិនអាចលុបលាង

បានដាច់ខាត ។ មុនព្រឹត្តិការណ៍ធ្ងន់ធ្ងរនេះកើតឡើង មន្ទីរពេទ្យកុមារ **គន្ធបុប្ផា** មានកំរិតការព្យាបាលស្មើនឹងមន្ទីរពេទ្យកុមារនៅបាងកក ។ អ្វីៗគ្រប់យ៉ាង ដែលបានកើតឡើងក្រោយឆ្នាំ ៧០ សុទ្ធតែជាផលវិបាក នៃព្រឹត្តិការណ៍ និង កំហុសធ្ងន់ធ្ងរទាំងឡាយ ដែលបណ្តាយមកពីពួកបស្ចិមប្រទេស ។ ទូលព្រះបង្គំមិនមែនជាអ្នកឯកទេសខាងជំនួយព្យាបាល ឬជាអ្នកឯកទេសខាងជំនួយអភិវឌ្ឍន៍ទេ ទូលព្រះបង្គំគ្រាន់តែធ្វើការក្នុងចំណោមបងប្អូនខ្មែរ ដែលមានមុខងារដូចគ្នា តំរង់ទៅរកគោលដៅតែមួយ : ការស្តារស្ថានភាពឡើងវិញ ។

តាមការពិត បងប្អូនគ្រូពេទ្យខ្មែរ ទើបជាអ្នកឯកទេស ។ គ្រូពេទ្យខ្មែរជាច្រើន តែងនិយាយប្រាប់ទូលព្រះបង្គំ ថា : " យើងខ្ញុំខ្វះខាតទឹកចិត្តធ្វើការក្នុងលក្ខខ័ណ្ឌល្អត្រឹមត្រូវ ។ យើងខ្ញុំលែងមានមធ្យោបាយចាំបាច់ ដើម្បីអាចដឹងអោយបានច្បាស់លាស់ពីរោគសញ្ញាជម្ងឺ ហើយយើងខ្វះខាតថ្នាំ ដែលមានគុណភាពល្អៗ ដើម្បីព្យាបាលអ្នកជម្ងឺ ប្រកបដោយប្រសិទ្ធិភាព "។ ដូចនេះ ទូលព្រះបង្គំ បានរៀបចំមធ្យោបាយសំរួលការរករោគសញ្ញា បាននាំមកនូវថ្នាំទាំងឡាយដែលមានគុណភាព ដូចថ្នាំដែលប្រើចំពោះពួកកុមារ នៅប្រទេសស្វីស ។ លើសពីនេះទៀត ទូលព្រះបង្គំ បានឧបត្ថម្ភប្រាក់រង្វាន់បន្ថែម អោយគ្រូពេទ្យខ្មែរទាំង ១៨០ នាក់ ដែលធ្វើការនៅមន្ទីរពេទ្យកុមារ **គន្ធបុប្ផា** ។ ប្រាក់រង្វាន់បន្ថែមដែលអាចអោយរស់បាន ។ សូមអញ្ជើញទៅរកអោយបានវេជ្ជបណ្ឌិតនៅប្រទេសអឺរ៉ុប ឬគិលានុប្បដ្ឋាកយិកា នៅប្រទេសអឺរ៉ុប ដែលមានទឹកចិត្តធ្វើការងារត្រឹមត្រូវ ដោយទទួលបានតែប្រាក់បៀវត្ស ដែលមិនអាចអោយរស់បាននោះចុះ ។ ដូចនេះ គ្រូពេទ្យខ្មែរទាំងអស់នេះ និយាយត្រូវ ។ ទូលព្រះបង្គំ បានបង្ហាញអោយឃើញថាអាចនឹងធ្វើអោយមានប្រព័ន្ធមួយ ដែលមានដំណើរប្រកបដោយប្រសិទ្ធិភាព និង មិនពុករលួយ ។ ពួកអ្នកដែលធ្វើការនៅមន្ទីរពេទ្យកុមារ **គន្ធបុប្ផា** សុទ្ធតែមានទឹកចិត្តធ្វើការ ។ ហើយការធ្វើអោយមានលក្ខខ័ណ្ឌទាំងនេះ ដែលអាចធ្វើអោយមានទឹកចិត្តដូចនេះ គួរតែក្លាយជាកាតព្វកិច្ច របស់ពួកបស្ចិមប្រទេស ទុកជាការលុបលាងកំហុស ។ ពួកអ្នកឯកទេស និង ពួកគ្រូពេទ្យ ប្រាប់យើងខ្ញុំថា : " តែនៅប្រទេសកម្ពុជាគ្មានមធ្យោបាយទេ ! " ។

ឯកឧត្តម បណ្តាអង្គទូតនានា ខ្ញុំសូមអញ្ជើញអស់លោក មកកាន់មន្ទីរពេទ្យកុមារ **គន្ធបុប្ផា** ដើម្បីមើលឃើញអ្វីៗ ដែលគេអាចធ្វើបាន ដោយទឹកប្រាក់ចំនួនតិចតួចប៉ុណ្ណោះ ។ ចាប់តាំងពីមន្ទីរពេទ្យមានដំណើរការឡើងវិញ នៅឆ្នាំ ១៩៩២ មក ដោយប្រើទឹកប្រាក់ចំនួន ១៣ លានដុល្លាអាមេរិក តែ ១៣ លានដុល្លាអាមេរិកប៉ុណ្ណោះ យើងខ្ញុំបានសាងសង់ពហុមណ្ឌលសំរាកព្យាបាល ដែលមានគ្រែចំនួន ២៤០ មានផ្នែក រ៉ាឌីយ៉ូឡូស៊ី អេកូក្រាហ្វី និង ហ្វីយស្សូរ៉ូស្កូពី ពីរកន្លែង មន្ទីរពេទ្យពិសោធន៍ ជីវសាស្ត្រ គ្លីនិចមួយ ដែលប្រើម៉ាស៊ីនប្រព័ន្ធកុំព្យូទ័រ ( ធ្វើការវិភាគចំនួន ១៨០ ក្នុងមួយថ្ងៃ ) កន្លែងបរិច្ចាគឈាម មន្ទីរពិសោធន៍ ខាងការស្រាវជ្រាវមេរោគ គឺថា សេរ៉ូឡូស៊ី និង មីក្រូប៊ីយ៉ូឡូស៊ី ដែលប្រកបដោយវិធីទំនើបៗ

សំរាប់ការរករោគសញ្ញាជម្ងឺរបេងទៀតផង ផ្នែកវះកាត់មួយដែលមានបន្ទប់វះកាត់ពីរ ប្រដាប់រំងាប់មេរោគទំនើបមួយ និង មណ្ឌលទទួលពិនិត្យជម្ងឺ និង ការពារព្យាបាល ។

ក្នុងចំនួនទឹកប្រាក់ ១៣លាន យើងបានចាយវាយ ពិសេសសំរាប់ការពិនិត្យជម្ងឺចំនួន ៣៥០.០០០ នាក់ ( បានធ្វើការពិនិត្យជម្ងឺចំនួន ៤៤០.០០០ ផង ) ទទួលកុមារចំនួន ២៥.០០០ នាក់ អោយសំរាកព្យាបាលវះកាត់ជម្ងឺកុមារចំនួន ៣.៥០០នាក់ ។ បើគ្មានមធ្យោបាយសំរួលការងារជាធរមានទាំងនេះ នៅមន្ទីរពេទ្យកុមារ **គន្ធបុប្ផា** ទេ កុមាររាប់ពាន់នាក់នឹងត្រូវស្លាប់ ដោយគ្មានការព្យាបាលដែលសមស្រប ។ ក្នុងចំនួនទឹកប្រាក់ ១៣ លាននេះ ក៏មានរាប់បញ្ចូលទាំងប្រាក់រង្វាន់បន្ថែម សំរាប់គ្រូពេទ្យ ចំណាយសំរាប់អគ្គិសនី ( ម៉ាស៊ីនភ្លើងធំៗពីរ ដែលដើរ ២៤ ម៉ោងលើ ២៤ ម៉ោង ) ព្រមទាំងប្រាក់សំរាប់ជួសជុលផងដែរ ។ ហើយទាំងអស់នេះ រហូតដល់ពេលសព្វថ្ងៃ គំរូវអោយប្រើទឹកប្រាក់តែ ១៣ លានប៉ុណ្ណោះ ។ យើងប្រើតែ បីភាគរយ នៃ ចំនួនទឹកប្រាក់នេះ សំរាប់ការងាររដ្ឋបាល ។

អ្វីៗទាំងអស់នេះ បានអនុញ្ញាតអោយមានការស្រាវជ្រាវ រកឃើញសំខាន់ៗខាងផ្នែកវេជ្ជសាស្ត្រ ការស្រាវជ្រាវរកឃើញ ដែលអាចមានដោយសារវិធីចាំបាច់ទាំងឡាយ នៅពេលដែលគេចង់ធ្វើអោយមានវេជ្ជសាស្ត្រមួយជាក់ស្តែង និង ត្រឹមត្រូវ ។ មានការស្រាវជ្រាវរកឃើញខ្លះ ការសង្កេតខ្លះៗ ដែលយើងចេញផ្សាយហើយ ឬក៏កំពុងរៀបចំចេញផ្សាយ ។

បើគិតអោយសព្វទៅ មានតែមន្ទីរពេទ្យដែលមានប្រដាប់ប្រដារគ្រប់គ្រាន់ និង មានដំណើរការធម្មតាទេ ទើបអាចមានលទ្ធភាព ឧបត្ថម្ភដល់ការអប់រំ និង ការបណ្តុះបណ្តាលចំណេះដឹងជារៀងរាល់ថ្ងៃ ចំពោះពួកនិស្សិត ពួកកម្មសិក្សាការី និង ពួកនិស្សិតពេទ្យឆ្នាំបញ្ចប់ និង ពួកគិលានុបដ្ឋាកយិកាបាន ។ ការបណ្តុះបណ្តាលនេះ ចំណេះដឹងនឹងមានតម្លៃ បើសិនជាការនេះប្រព្រឹត្តិទៅនៅក្នុងក្របខ័ណ្ឌ ( មណ្ឌល) មន្ទីរពេទ្យ និងប្រឈមមុខនឹងជម្ងឺទាំងឡាយ ដែលមាននៅប្រទេសកម្ពុជា មិនមែននៅប្រទេសអឺរ៉ុបទេ ។ ការបណ្តុះបណ្តាលជាប្រចាំនេះ ដែលយើងខ្ញុំរៀបចំអោយមានពីរឆ្នាំកន្លះហើយនោះ ហើយដែលត្រូវរាប់បញ្ចូលក្នុងថវិការួមដែរ ជាតំណាងការបណ្តាក់ទុនរយៈពេលវែង សំរាប់ប្រទេសកម្ពុជា ។ ពួកអ្នកឯកទេសក៏និយាយថា : " តែទោះជាយ៉ាងណា ក៏ត្រូវមានទឹកប្រាក់ ១៣ លាន នេះដែរ " ។ មែនពិតជាត្រឹមត្រូវ ។ គ្មានប្រាក់ គ្មានធ្វើអ្វីបានទេ ។ ដូចនេះហើយ ទើបយើងខ្ញុំខំរកប្រាក់នេះរាល់ថ្ងៃ ។ គឺជាការតស៊ូមួយដ៏ស្វិតស្វាញ ។ ដោយសារតែទឹកចិត្តសាមគ្គីរបស់ប្រទេសស្វីស ទើបយើងអាចទទួលបានទឹកប្រាក់នេះ ហើយទូលព្រះបង្គំ សូមឆ្លៀតយកឱកាសនេះ ដើម្បីថ្លែងអំណរគុណយ៉ាងខ្លាំងក្លាបំផុត ចំពោះសប្បុរសជនរាប់ពាន់នាក់ ដែលបានទុកចិត្តលើពួកយើងខ្ញុំ ។ អំណោយភាគច្រើន ជាអំណោយរបស់ឯកជន និង អំណោយសប្បុរសជន ដែលមកពីប្រទេសស្វីស ជាពិសេសពីព្រោះគំរោង **គន្ធបុប្ផា** ត្រូវបានស្គាល់ និង ទទួលស្គាល់ ជាពិសេសនៅប្រទេសស្វីស ដោយសារដំណើរការប្រកបដោយប្រសិទ្ធិភាពជាក់ស្តែង និង

ភាពស្អាតស្អំរបស់គំរោងនេះ ។ ឥឡូវនេះ ទូលព្រះបង្គំ សូមអញ្ជើញអស់លោកអ្នកទាំងឡាយ ដែលអាចជួយយើងខ្ញុំបាន សូមមកចូលរួមជាមួយយើងខ្ញុំ ក្នុងគំរោងខាងលើនេះ។ ពីព្រោះការបង្កើតមណ្ឌលសាខាទាំងឡាយតាមគំរូ **គន្ធបុប្ផា** ជាដំណោះស្រាយដ៏ប្រសើរមួយ សំរាប់ដោះស្រាយបញ្ហាសុខភាពរបស់កុមារនៅព្រះរាជាណាចក្រកម្ពុជា ។

បញ្ហាសុខភាពមួយ ក្នុងចំណោមបញ្ហាសុខភាពធំៗ នៅប្រទេសកម្ពុជា គឺជម្ងឺរបេង ។ ពីអាទិត្យមុន យើងបានរកឃើញរោគសញ្ញារបេងខួរក្បាលលើមនុស្ស ៩ នាក់ នេះជាសណ្ឋានរបេងដែលធ្ងន់ធ្ងរជាងគេបំផុត ។ ដោយសារតែគ្រឿងប្រដាប់ និង ការបណ្តុះបណ្តាលចំណេះដឹងរបស់យើង យើងខ្ញុំរកឃើញករណីដែលមានជម្ងឺរបេងថ្មីៗរាល់ថ្ងៃ ( ពី ៥ ទៅ ១៥ ករណីក្នុងមួយថ្ងៃ ) ។ យើងបានសង្កេតឃើញថា ករណីនៃការខ្វះជាតិចំណីអាហារចំនួនជាងពាក់កណ្តាល ត្រូវបណ្តាលឡើងដោយសារជម្ងឺដ៏ធ្ងន់ធ្ងរនេះ ។ គេគ្រាន់តែព្យាបាលកុមារតាមរបៀប Rifater ដែលគេប្រើនៅប្រទេសស្វីស និង សហរដ្ឋអាមេរិកប្រឆាំងនឹងជម្ងឺរបេង នោះគេឃើញកុមារទាំងនោះ ចាប់ទទួលទានអាហារតាំងតែពីពេលប្រើថ្នាំនោះ បានបួនថ្ងៃ ។ ជម្ងឺរាករូសច្រើនយ៉ាង ត្រូវបានបណ្តាលពីជម្ងឺរបេងដែរ ។ គ្មានកុមារណាម្នាក់ ដែលមកមន្ទីរពេទ្យយើងខ្ញុំដោយសារមានជម្ងឺរបេងទេ តែដោយសាររងការទទួលមេរោគបាក់តេរីច្រើនហួស ( Surinfection bactérienne ) សភាពនេះមានកំរិតកាន់តែធ្ងន់ធ្ងរ ដោយសារសមត្ថភាពប្រឆាំងនឹងជម្ងឺរបស់រាងកាយត្រូវចុះខ្សោយដោយសារជម្ងឺរបេង ។ នៅមិនទាន់មានរបៀបការពារដែលមានប្រសិទ្ធិភាពពិតប្រាកដ ដើម្បីដោះស្រាយបញ្ហានេះនៅឡើយទេ ។ ត្រូវតែព្យាបាលអ្នកជម្ងឺទាំងអស់នឹងអ្នកដែលអាចចំលងជម្ងឺទាំងអស់ដើម្បីបំបាត់ការឆ្លងរាលដាលជាបន្ត ។ ជម្ងឺរបេងក៏ជាផលវិបាកផ្ទាល់មួយ នៃ សង្គ្រាមដែរ ព្រោះគេបានកត់សំគាល់ឃើញជម្ងឺរបេងកើនចំនួនឡើង នៅក្នុងប្រទេសដែលកំពុងមានសង្គ្រាមទាំងអស់ ។

ក្រៅពីនេះ ជម្ងឺផ្សេងទៀតក៏ជាផលវិបាក នៃ សង្គ្រាមដែរ ឧទាហរណ៍ ដូចជាទារកដែលកើតមកមានរូបរាងមិនធម្មតា កាន់តែមានចំនួនច្រើនឡើង ។ ម្តាយៗរបស់ទារកទាំងនោះ ជាប្រជាជន នៅតំបន់ទាំងនោះ ដែលគេប្រើសារធាតុ ឌីអុកស៊ីន ( Dioxine ) ជាសារធាតុសំរាប់ធ្វើអោយស្វិតឈើជ្រុះ។ យើងខ្ញុំក្រុមគ្រូពេទ្យវះកាត់របស់ទូលព្រះបង្គំ យើងខ្ញុំ ក្រោមការដឹកនាំរបស់គ្រូពេទ្យវះកាត់ Dr. Gabriel fean ដែលជាជនជាតិកាណាដា បានធ្វើការវះកាត់រាងកាយខុសធម្មតានេះជាច្រើន ។ ការនេះក៏មិនមែនជាជំនួយដែរ តែជាការលុបលាងកំហុស ។

ស្ថានភាពសុខភាពរបស់កុមារនៅកម្ពុជាធ្ងន់ធ្ងរណាស់ ។

កុមារ បេះដូងរបស់ប្រទេសនិមួយៗ ព្រលឹងរបស់ប្រទេសនិមួយៗកំពុងរងទុក្ខ ។ ដោយសារតែព្រះករុណា ព្រះអង្គប្រោសប្រទានថ្ងៃដីនេះដល់ទូលព្រះបង្គំ យើងខ្ញុំ ដើម្បីអោយទូលព្រះបង្គំ យើងខ្ញុំអាច

ពង្រីកលទ្ធភាពរបស់ខ្លួន និង អាចមិនបង្ខំចិត្តមិនទទួលអ្នកជម្ងឺនោះ ព្រះករុណា ទ្រង់បានបង្ហាញទូលព្រះបង្គំ យើងខ្ញុំ នូវ ផ្លូវដែលជួយអោយ ទូលព្រះបង្គំ យើងខ្ញុំព្យាបាល បន្តខំប្រឹងប្រែងតទៅទៀត ដោយដោយបំពេញការងារស្របទៅតាមមនសិការវិជ្ជាជីវៈដ៏ប្រសើររបស់ ទូលព្រះបង្គំ យើងខ្ញុំ ។

ថ្ងៃនេះ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ជាថ្ងៃចាប់ផ្តើមការសាងសង់សាខាមន្ទីរពេទ្យកុមារ គន្ធបុប្ផា លើផ្ទៃដីមួយផ្នែកក្នុងបរិវេណព្រះបរមរាជវាំងដែល ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន និង សម្តេច ព្រះមហេសី ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ប្រោសប្រទានដល់ទូលព្រះបង្គំ យើងខ្ញុំ ។

ទូលព្រះបង្គំ យើងខ្ញុំ សូមសំដែងអំណរព្រះគុណដោយរំភើបចិត្ត ថ្វាយចំពោះ ព្រះករុណា ជាអម្ចាស់ ព្រះមហាក្សត្រ ចំពោះព្រះរាជហឫទ័យសប្បុរសរបស់ព្រះអង្គនេះ អាចនឹងជួយការពារសុខភាពកុមារ ដែលមានជម្ងឺជាច្រើននៅព្រះរាជាណាចក្រ កម្ពុជា ។

ព្រះករុណា ជាអម្ចាស់ , សម្តេច ព្រះមហេសី ,

សម្តេច , ឯកឧត្តម , លោកជំទាវ , អស់លោក និង លោកស្រី

ទូលព្រះបង្គំ សូមអរព្រះគុណ សូមអរគុណ ។

Dr. BEAT RICHNER

( វេជ្ជបណ្ឌិត ប៊ីត រីចនឺរ )